***Common Issues Identified by all Reports:*** ● (1) Need for clear land demarcation involving consultation with neighboring communities and authorities. ● (2) Need for communal land titling. ● (3) Need for community networking and mobilizing. ● (4) Need for community-based management of forest and water resources. ● (5) Need for sustainable livelihoods in the light of lessening dependency on swidden. ● (6) Need for accountability of local government and leadership.

# ការកំណត់ព្រំប្រទល់ដីច្បាស់លាស់

## CLEAR LAND DEMARCATION

## ១. ការកំណត់ព្រំប្រទល់ដីច្បាស់លាស់

- ក្នុងតំបន់ដែលមានការកំណត់ព្រំប្រទល់ដីច្បាស់លាស់ មិនមានការបាត់បង់ដីធ្លីនិងទំនាស់ដីធ្លីទេ (ឧទាហរណ៍ នៅក្រាឡា 0%
- ភស្តុតាងអំពីកំណើនឧប្បត្តិហេតុនៃទំនាស់ព្រំប្រទល់ដីធ្លី ក្នុងរង្វង់និងរវាងអ្នកភូមិនិងឃុំ។
- ការលក់ដី ផ្តើមដោយភាគីដែលមានសិទ្ធិលើដីធ្លីត្រឹមត្រូវតាមច្បាប់តិចតួចបំផុត ។
- ការខ្វះខាតរបៀបរបបកាន់កាប់ដីធ្លីប្រកបដោយសុវត្ថិភាព ធ្វើឱ្យអ្នកកាន់កាប់ដីរាថយពីការវិនិយោគឱ្យប្រសើរឡើង។
- នីតិវិធីគូសផែនទីបច្ចុប្បន្នគឺជាការចាប់ផ្តើមដ៏ល្អមួយ ប៉ុន្តែជាញឹកញយ ខ្វះខាតនូវការប្រឹក្សាយោបល់ឱ្យបានពេញលេញជាមួយសមាជិកសហគមន៍ទាំងអស់និងសហគមន៍ជិតខាង។ មានសេចក្តីត្រូវការដ៏ចាំបាច់ក្នុងការកំណត់ព្រំប្រទល់ភូមិ ។

---

**1) Clear Land Demarcation: In areas with clearly demarcated land there is less land loss and conflict (e.g. Krala, 0%).** ● Evidence of increasing incidence of boundary disputes within and between villages and communes. ● Land sales initiated by party with the least legitimate claim to the land. Lack of secure land tenure discourages land holders from investing in improvements. ● Current mapping procedures are a good start, but often lack full consultation of all community members and neighboring communities. There is a critical need for village boundary demarcation.

Tuy Village
(MAP1)

# ភូមិទុយ

- ផ្លូវធំ/សំខាន់
- ព្រំប្រទល់ភូមិ
- ដីមិនធ្វើកសិកម្ម
- ដីព្រៃទំនេរ
- ដីទំនេរ និងកូនដើមស្វាយចន្ទី
- កសិកម្ម
- ដីស៊ើម, ជាអចិន្ត្រៃ/តិណទេស
- ទឹក
- ការតាំងភូមិលំនៅ



**_Tuy Village:_**
**_Land cover in PLUP Agricultural Land_**

# ភូមិទុយ

- ផ្លូវធំ/សំខាន់
- ព្រំប្រទល់ភូមិ
- ដីមិនធ្វើកសិកម្ម
- ដីព្រៃការពារ
- ដីទំនេរ និងកូនដើមស្វាយចន្ទី
- កសិកម្ម
- ដីសើម, ជាអចិន្ត្រៃ/តិណទេស
- ទឹក
- ការតាំងភូមិលំនៅ

*Tuy Village:*
*Land cover in PLUP Agricultural Land*

Krala Village
(Map1)

# ភូមិក្រាឡា

ផ្លូវធំ/សំខាន់
ព្រំប្រទល់ភូមិ
ដីព្រៃទំនេរ
ដីទំនេរ និងកូនដើមស្វាយចន្ទី
កសិកម្ម
ស្រែស្រូវ
ការតាំងភូមិលំនៅ
ដីមិនធ្វើកសិកម្ម

***Krala Village:***
***Land cover in PLUP Agricultural Land***

# ភូមិក្រាឡា

*Krala Village:*
*Land cover in PLUP Agricultural Land*

Leu Khun
Village (Map1)

# ភូមិឡឺឃុន

ផ្លូវធំ/សំខាន់

ព្រំប្រទល់ភូមិ

ដីព្រៃទំនេរ

ដីទំនេរ និងកូនដើមស្វាយចន្ទី

កសិកម្ម

ទឹក

ការតាំងភូមិលំនៅ

ដីមិនធ្វើកសិកម្ម

**_Leu Khun Village:_**
**_Land cover in PLUP Agricultural Land_**

# ភូមិឡឺឃុន

ផ្លូវធំ/សំខាន់

ព្រំប្រទល់ភូមិ

ដីព្រៃការពារ

ដីទំនេរ និងកូនដើមស្វាយចន្ទី

កសិកម្ម

ទឹក

ការតាំងភូមិលំនៅ

ដីមិនធ្វើកសិកម្ម

**Leu Khun Village:**
*Land cover in PLUP Agricultural Land*

# កម្មសិទ្ធិដីសហគមន៍
## COMMUNAL LAND

## ២. កម្មសិទ្ធិដីសហគមន៍ :

- មិនមានការចេញនូវប័ណ្ណកម្មសិទ្ធិដីធ្លីទេ, ៧ ឆ្នាំហើយ តាំងតែពីច្បាប់ភូមិបាលបានអនុម័តមក។
- ប្រជាពលរដ្ឋជនជាត់ដើមភាគតិច មានការពិបាកយល់ទិដ្ឋភាពច្បាប់ស្តីពីកម្មសិទ្ធិសហគមន៍
- សហគមន៍ចងបានចម្រុះគ្នា គឺទាំងកម្មសិទ្ធិដីជាបុគ្គលផង និងសហគមន៍ផង ដើម្បីតម្រូវសេចក្តីត្រូវការកម្មសិទ្ធិបច្ចុប្បន្ន :
  - ▶ សិទ្ធិលើដីឯកជនសម្រាប់កសិកម្ម និងលើដីលំនៅដ្ឋាន
  - ▶ សិទ្ធិលើដីសហគមន៍សម្រាប់ព្រៃអារក្ស និងលើដីបម្រុងសម្រាប់ការធ្វើស្រែចំការអនាគត។
- សេចក្តីព្រាងអនុក្រិត្យបច្ចុប្បន្នអំពីការចុះបញ្ជីដីធ្លីជនជាត់ដើមភាគតិច គឺជាការចាប់ផ្តើមល្អមួយ ប៉ុន្តែត្រូវការនូវវិសុទ្ធកម្ម ដើម្បីដោះស្រាយឱ្យបានពេញលេញនូវកង្វល់ទាំងឡាយរបស់ជនជាតិដើមភាគតិច។

---

***2) Communal Land Titling:*** No titles yet issued 7 years after Land Law passed.● Indigenous Peoples have difficulty in understanding legal aspects of communal titling. ● Communities want a mixture of individual and communal title to suit current ownership needs:- private land rights for agricultural and residential lands; -communal rights for spirit forests and reserve land for future cultivation.
●Current draft Sub-Decree on Indigenous Land Registration is a good start, but needs refining to fully address concerns of IPs.

# ការបង្កើតបណ្តាញសហគមន៍
# COMMUNITY NETWORKING

## ៣. ការបង្កើតបណ្តាញសហគមន៍ :

- សហគមន៍ដែលមានស្ថាប័នប្រពៃណីនិងសាមគ្គីភាពរឹងមាំ មានទំនាស់ដីធ្លីតិចជាង និងមានបញ្ហាតិចតួចជាមួយនឹងការផ្លាស់ប្តូរដី។

- សហគមន៍ដែលប្រឈមមុខនឹងការផ្លាស់ប្តូរដី ឬដែលស្ថាប័នប្រពៃណីរបស់ពួកគេត្រូវការការពង្រឹង អាចទទួលបានប្រយោជន៍ពីឧទាហរណ៍របស់សហគមន៍ដែលមានជោគជ័យច្រើន។

***3) Community Networking:*** ● Communities which have strong traditional institutions and solidarity have less land conflicts and fewer problems with land alienation. ● Communities facing land alienation or whose traditional institutions need strengthening could benefit from examples of more successful communities.

# ការគ្រប់គ្រងព្រៃឈើ និងធនធានទឹកសហគមន៍ :

## Community Management of Forest and Water Resources

## ៤. ការគ្រប់គ្រងព្រៃឈើនិងធនធានទឹកសហគមន៍ :

- សហគមន៍ដែលជាប់ពាក់ព័ន្ធក្នុងការគ្រប់គ្រងដីធ្លី ដោយមានការបន្តគាំទ្រពីអង្គការក្រៅរដ្ឋាភិបាលមានដីសហគមន៍គ្រប់គ្រងយ៉ាងជោគជ័យ និងមាននិរន្តរភាព (ភូមិក្រឡា រតនគីរី)

- សមាគមន៍អនុផលព្រៃឈើផ្អែកលើសហគមន៍មូលដ្ឋាន មានជោគជ័យខ្លះៗក្នុងការអភិរក្ស និងចេញចូលទៅរកធនធានព្រៃឈើជាប្រពៃណី (មណ្ឌលគីរី)។

- ការបាត់បង់ដី បង្ខំឱ្យអ្នកភូមិផ្លាស់ប្តូរទៅកាន់ទីព្រៃ និងកាប់ឆ្ការព្រៃឆ្ងាយៗកាន់តែច្រើនឡើងៗ (ភូមិទុយ រតនគីរី)

- ការគ្រប់គ្រងធនធានធម្មជាតិផ្អែកលើសហគមន៍ខ្វះការទទួលស្គាល់និងការគាំទ្រពីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍

---

***4) Community Management of Forest and Water Resources:*** ● Communities engaged in land management with ongoing NGO support have successfully and sustainably managed community lands (Krala village, Ratanakiri). ● Local community-based NTFP associations have some success in conservation and access to traditional forest resources (Mondulkiri). ● Land loss is forcing villagers to move to and clear more remote forests (Tuy village, Ratanakiri). ● Community-based natural resource management lacks recognition and support from Government and development partners.

# ការផ្លាស់ប្តូរគម្របដីធ្លីនិងចំនួនប្រជាពលរដ្ឋ
# CHANGES IN LAND COVER AND POPULATION

## ការផ្លាស់ប្តូរគម្របដីធ្លី និងចំនួនប្រជាពលរដ្ឋ
## ការប្រៀបធៀបភូមិចំនួន ៣ នៅក្នុងខេត្តរតនគិរី

| | ភូមិ/ឆ្នាំ Village/Year | ក្រឡា Krala | | ឡឺឃុន Leu Khum | | ទុយ Tuy | |
|---|---|---|---|---|---|---|---|
| គម្របដីដែលបានធ្វើផែនទី Land cover as mapped | | 1989 | 2006 | 1989 | 2006 | 1989 | 2006 |
| ព្រៃ Forest | ហិកតា Ha | 2479 | 2142 | 1034 | 782 | 1143 | 488 |
| | ភាគរយនៃគម្របដី % of Land Cover | 94 | 81 | 65 | 49 | 79 | 34 |
| | ហិកតាបាត់បង់/ឆ្នាំ Ha lost/year | 20 | | 15 | | 39 | |
| | អត្រាប្រចាំឆ្នាំនៃការផ្លាស់ប្តូរជាភាគរយ Annual Rate of Change % | -0.86% | | -1.63% | | -4.83% | |
| | ឆ្នាំសល់ក្រោមអត្រាបាត់បង់បច្ចុប្បន្ន Year left under current lost rate | 108 | | 53 | | 12 | |
| | ហិកតា / ម្នាក់ Ha/Person | 11 | 5 | 3 | 1 | 5 | 1 |

Changes in Land Cover and Population
Comparison of the 3 Villages in Ratanakiri

# ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព
## SUSTAINABLE LIVELIHOODS

## ៥. ការចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព :

- ការខ្វះខាតឱកាសខាងសេដ្ឋកិច្ចនិងចំណូលទៀងទាត់ បង្កើនឱ្យមានភាពប្រថុយប្រថានក្នុងការលក់ដីធ្លីអំឡុងពេលគ្រួសារជួបវិបត្តិ (ឧទាហរណ៍ ជំងឺ, ការខ្វះខាតអាហារ, ។ល។)

- អសន្តិសុខដីធ្លីកើតមកពីការចាកចេញពីកសិកម្មវិលវិលដោយគ្មានជម្រើសច្បាស់លាស់ ឬដោយគ្មានការណែនាំលើប្រសិទ្ធិភាពអនុវត្តការដាំដំណាំយកផលឱ្យបានច្រើនផងលើដី។

- អាជ្ញាធរមូលដ្ឋានបានថ្លែងថា ជនជាតិដើមភាគតិចគឺ "ប្រឆាំងការអភិវឌ្ឍន៍"។ ប៉ុន្តែ ជនជាតិដើមភាគតិចបានសម្តែងការចង់បានការអភិវឌ្ឍន៍សេដ្ឋកិច្ចច្បាស់លាស់ ប៉ុន្តែវាគួរស្ថិតក្រោមការត្រួតត្រារបស់ពួកគេ និងជាប់លាប់ស្របទៅតាមជំនឿនិងវប្បធម៌របស់ពួកគេ។ ឧទាហរណ៍ ...

---

***5) Sustainable Livelihoods:*** ● Lack of secure income/economic opportunities increases the risk of land sales during times of family crisis (e.g. illness, food shortage, etc.). ● Land insecurity results in a departure from swidden agriculture, without clear alternatives or guidance on effective practices in intensive agriculture. ● Local authorities have stated perceptions that indigenous peoples are "anti-development". However, indigenous people have expressed a clear desire for economic development, but it should be under their control, sustainable and consistent with their beliefs and culture. For example…

# បាតុភូតផ្លែស្វាយចន្ទី
# CASHEW PHENOMENON

## បាតុភូតផ្លែស្វាយចន្ទី :

- ✔ ការទុកចិត្តជាសកលលើផលិតផលគ្រាប់ស្វាយចន្ទី ក្នុងការផ្តល់ចំណូលជាលុយកាក់ នាំឱ្យមានការរីកចម្រើនកាន់តែច្រើនឡើងៗ
- ✔ ការច្របាច់បញ្ចូលការដាំដុះស្រូវនិងចំការស្វាយចន្ទីលើដីទួលបានរីកឡើង
- ✔ បង្ហាញនូវសមត្ថភាព/ឆន្ទៈរបស់ជនជាតិដើមភាគតិច ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច
- ✔ មានកម្រិត និងត្រួតត្រាបានតែក្នុងភូមិក្រាឡាតាមរយៈផែនការប្រើប្រាស់ដីធ្លី
- ✔ កង្វះខាតការត្រួតត្រា នាំឱ្យព្រៃឈើថយចុះ

***Cashew Phenomenon:*** ✓ Universal reliance on cashew nut production for cash income, leading to greater prosperity. ✓ Integration of upland rice and cashew plantations driving expansion. ✓ Demonstrates Indigenous capacity/willingness to engage in economic development. ✓ Limited and controlled only in Krala through land use planning. ✓ Lack of controls may lead to forest depletion.

Accountability of Local Government and Leadership

# ការទទួលខុសត្រូវរបស់រដ្ឋាភិបាលមូលដ្ឋាន និងភាពជាអ្នកដឹកនាំ

***Accountability of Local Government and Leadership***

## ការទទួលខុសត្រូវរបស់រដ្ឋាភិបាលមូលដ្ឋាន និងភាពជាអ្នកដឹកនាំ :

- សហគមន៍កាន់តែមានសុវត្ថិភាពនិងកាន់តែរីកចម្រើន នៅពេលដែលមេដឹកនាំភូមិឃុំចែករំលែកព័ត៌មាន និងការធ្វើសេចក្តីសម្រេចចិត្ត។
- ការតែងតាំងមេភូមិដោយមេឃុំ (ឧ. ភូមិឡឺឃុន) ផាត់ចោលអ្នកភូមិពីដំណើរការធ្វើសេចក្តីសម្រេចចិត្ត និងលើកតម្កើងជានិរន្តន៍នូវរចនាសម្ព័ន្ធគ្រប់គ្រងបែបជិះជាន់។
- សហគមន៍ជាទូទៅ គន់មើលមន្ត្រីរដ្ឋាភិបាល ដែលទទួលខុសត្រូវចំពោះការលក់ដី និងមិនឆ្លើយតបទៅនឹងបណ្តឹងតវ៉ារបស់ពួកគេ។
- អភិបាលខេត្តមណ្ឌលគិរី ទទួលស្គាល់បញ្ហាចាប់ច្បាមយកដីធ្លី និងហាមឃាត់អាជ្ញាធរស្រុក, ឃុំ និងភូមិ មិនឱ្យផ្តល់សេចក្តីយល់ព្រមលើការលក់ដូរដី ដោយគ្មានការអនុញ្ញាតពីរូបគាត់ឡើយ។
- អំពើពុករលួយជាបញ្ហាមួយនៅគ្រប់កម្រិតទាំងអស់របស់អាជ្ញាធរមូលដ្ឋាន។

---

***6) Accountability of Local Government and Leadership:*** ● Communities are more secure and prosperous when Village and Commune Leaders share information and decision-making. ● Appointment of Village Chief by Commune Chief (e.g. Leu Khun) excludes villagers from the decision-making process and perpetuates domination structures. ● Communities generally view Government officials as responsible for land sales and not responsive to their complaints. ● Governor of Mondulkiri recognizes land-grabbing problem and prohibited district, commune and village authorities from approving land sales without his permission. ● Corruption is a problem on all levels of local authorities.

# សេនារីយ៉ូអនាគត

## FUTURE SCENARIOS



# អនុសាសន៍

## RECOMMENDATIONS

- កម្រិតព្រំប្រទល់ដីច្បាស់លាស់ ដោយមានការចូលរួមប្រឹក្សាយោបល់ជាមួយសហគមន៍ជិតខាង និង អាជ្ញាធរ។ រួមទាំងការកំណត់នូវការអះអាងសំរាប់ចុះបញ្ជីដីសហគមន៍។

- ឱ្យមានសុវត្ថិភាពកម្មសិទ្ធិដីសហគមន៍ និង វិធានការបណ្តោះអាសន្នរហូតដល់បញ្ហានេះអាចធ្វើទៅបាន។

- គាំទ្របណ្តាញសហគមន៍និងប្រមូលផ្តុំសហគមន៍។

- គាំទ្រការគ្រប់គ្រងព្រៃឈើនិងធនធានទឹកផ្អែកលើសហគមន៍។

- បង្កើនការគាំទ្រសំរាប់ចិញ្ចឹមជីវិតប្រកបដោយនិរន្តរភាព។

- ជួយអោយសហគមន៍ ដើម្បីរៀបចំរដ្ឋបាលមូលដ្ឋាន មានការទទួលខុសត្រូវខ្ពស់ និង ភាពជាអ្នកដឹកនាំ

# THANKS!

## សំណួរ/យោបល់
## Questions/Comments

# ដីសំរាប់កូនចៅរបស់ខ្ញុំ: ការប្រើប្រាស់ដី និងការផ្លាស់ប្តូរសិទ្ធិក្នុងខេត្តរតនៈគីរី

## ១៩៨៩_២០០៣

Jefferson M. Fox, Dennis McMahon,
Mark Poffenberger, and John Vogler

EAST-WEST CENTER

Community Forestry
INTERNATIONAL

ដូចក្នុងប្រទេសជាច្រើននៅអាស៊ីអាគ្នេយ៍ផងដែរ នៅក្នុងការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ៖ កម្ពុជាប្រឈមនឹងការ លំបាកជាច្រើនដែលទាក់ទងនឹងសិទ្ធិ និង វប្បធម៌នៃជនជាតិដើមភាគតិចដែលរស់នៅក្នុងតំបន់ខ្ពង់រាប ។ ការកសាងផែនការដែល ធ្វើឡើងនៅថ្នាក់កណ្តាល និងគោលដៅសេដ្ឋកិច្ច ដែលត្រូវបានរៀបចំឡើងសម្រាប់តំបន់ដាច់ស្រយាលទាំងនេះជាញឹកញាប់បានធ្វើឡើងដោយគ្មានការទទួលស្គាល់អំពីចំណេះដឹងប្លែកៗរបស់សហគមន៍ជនជាតិដើមភាគតិចអំពីបរិស្ថានរបស់ពួកគេ និងធនធាន ពិសេសៗដែលពួកគេអាចយកមកប្រើប្រាស់សម្រាប់ការអភិវឌ្ឍរបស់ខ្លួនឡើយ។ ជាផលវិបាកកិច្ចផ្តួចផ្តើមនានាក្នុងវិស័យសាធា-រណៈ និងឯកជនសម្រាប់អភិវឌ្ឍន៍ អាចមិនសូវមានភាពសមស្រប ឬមានទំនាស់ជាមួយតម្រូវការ និងប្រព័ន្ធគ្រប់គ្រងនៅមូលដ្ឋាន ដែលនាំឱ្យមានអស្ថិរភាពនៃការប្រើប្រាស់ដីធ្លី និងប្រព័ន្ធកម្មសិទ្ធិ ក៏ដូចជាប្រព័ន្ធសង្គមនានាផងដែរ។

នៅខេត្តរតនៈគិរី មានប្រមាណ ២៥០ ភូមិ ដែលមានប្រជាជនចំនួន ១០០.០០០ នាក់ រស់នៅ ឬមួយក្នុងព្រៃ ឬមួយនៅក្នុងចម្ងាយ៥គ.ម ពីព្រៃ។ អត្រាកំណើនចំនួនប្រជាជនប្រចាំឆ្នាំមាន ៤ ទៅ ៥% ដោយសារកំណើនពីធម្មជាតិ និងការធ្វើចំណាក ស្រុក រួមផ្សំជាមួយការពង្រីកយ៉ាងឆាប់រហ័សនៃទីផ្សារ ដែលកំពុងបង្កឱ្យមានសម្ពាធយ៉ាងខ្លាំងមកលើដីធ្លី និងព្រៃឈើ និង ជម្រុញឱ្យមានទីផ្សារដីធ្លីយ៉ាងធំ និងដែលល្មើសច្បាប់។ នៅពេលដែលសហគមន៍ជនជាតិដើមភាគតិចបាត់បង់សិទ្ធិត្រួតត្រាលើដីធ្លី ពួកគេត្រូវបង្ខំចិត្តដកថយចូលទៅរស់នៅក្នុងព្រៃដោយរានឆ្ការកន្លែងនោះសម្រាប់ការរស់នៅ។ តាមអត្រានៃការបាត់បង់ព្រៃឈើ សព្វថ្ងៃនេះ ព្រៃឈើយ៉ាងច្រើននៅក្នុងខេត្តរតនៈគិរីទំនងជានឹងត្រូវរានឆ្ការអស់នៅក្នុងទសវត្សរ៍ខាងមុខនេះ។ នៅក្នុងអំឡុង ពេលដូចគ្នានេះ ពាក់កណ្តាលនៃផ្ទៃដីរបស់ជនជាតិដើមភាគតិចនៅក្នុងខេត្តនេះទាំងមូល នឹងត្រូវផ្ទេរទៅឱ្យវិនិយោគិនមកពីក្រៅ ម្ចាស់ដីសម្បទាន ឬប្រជាពលរដ្ឋខ្មែរជាជនចំណាកស្រុកមកពីតំបន់វាលរាប។ ការបាត់បង់កម្មសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើម ភាគតិច បានធ្វើឱ្យមានកំណើនភាពទន់ខ្សោយខាងសង្គម និងសេដ្ឋកិច្ច ទាំងបច្ចុប្បន្ន និងទៅអនាគតចំណែកការរានឆ្ការព្រៃឈើធម្មជាតិ ទំនងជានឹងធ្វើឱ្យមានអស្ថិរភាពនៃទម្រង់មីក្រូអាកាសធាតុមានឥទ្ធិពលមកលើរបបជលសាស្ត្រនៃទីជម្រាល និងបាត់បង់ ជីវៈចម្រុះផងដែរ។ ការប្រែប្រួលនេះ អាចបង្កើតជាកត្តានានា ដែលដាក់កំហិតមកលើនិរន្តរភាពនៃប្រព័ន្ធផលិតកម្មសេដ្ឋកិច្ចថ្មីៗ ណាមួយ ដែលនឹងជំនួសទម្រង់នៃការប្រើប្រាស់ដីធ្លីដូចសព្វថ្ងៃនេះ( ពោលគឺ ព្រៃឈើ និង កសិកម្មពនេចរ) ។



ឯកសារនេះផ្អែកលើករណីសិក្សានានាបានពីសហគមន៍ចំនួនបីនៅក្នុងខេត្តរតនៈគិរី ដែលបង្ហាញអំពី កម្លាំងដែលជម្រុញ ឱ្យមានការផ្លាស់ប្តូរលើការប្រើប្រាស់ដីធ្លី និងកម្មសិទ្ធិ ក៏ដូចជា តើការគ្រប់គ្រងយ៉ាងមានប្រសិទ្ធិភាពដោយសហគមន៍ អាចផ្តល់ជាការតម្រង់ទិសបែបណាដែរ ដល់អន្តរកាលនៃការវិវត្តផ្នែកកសិកម្ម។ ការសិក្សានេះបានរួមផ្សំជាមួយទិន្នន័យដែលបានពីរូបថតពី អាកាស ទៅតាមពេលវេលាខុសៗគ្នា ពីឆ្នាំ១៩៨៩ ដល់ ២០០៦ សម្រាប់វាយតម្លៃការប្រែប្រួលនៃការប្រើប្រាស់ដីធ្លី និងដែលបង្ហាញពីទំនាក់ទំនងនៃទិន្នន័យទាំងនេះ ជាមួយការសង្កេតបានស៊ីជម្រៅនៅលើចំណុចភូមិសាស្ត្រជាក់ស្តែង និងការស្រាវជ្រាវខាង ផ្នែកសង្គមនៅក្នុងភូមិ-ទាំងបីនេះ។

វិធីសាស្ត្រនេះត្រូវបានបង្កើតឡើង ដើម្បីវាយតម្លៃអំពីថាតើ សហគមន៍ជនជាតិដើមភាគតិច ដែលធ្លាប់មានប្រវត្តិ គ្រប់គ្រងដីព្រៃដែលជាធនធានសម្ងហភាព កំពុងធ្វើការឆ្លើយតបបែបណាទៅនឹងកម្លាំងនិងសម្ពាធនៃទីផ្សារ បណ្តាលពីឈ្មួញរកស៊ី ដីធ្លី។ ភូមិក្រឡាបានទទួលការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដើម្បីពង្រឹងសហគមន៍ កសាងផែនទីដីធ្លីរបស់ភូមិនេះ កំណត់ព្រំប្រទល់ ពង្រឹងបទប្បញ្ញត្តិ អំពីការប្រើប្រាស់ធនធាន និងកសាងផែនការប្រើប្រាស់ដីធ្លី។ នៅពេលក្រោយមក ភូមិទុយ និងភូមិឡឺគើន បានទទួលការគាំទ្រពីអង្គការមកពីខាងក្រៅក្នុងកម្រិតតិចតួចជាង ដើម្បីកសាងផែនទីធនធាន ដោយគ្មានការគាំទ្រសម្រាប់ការពង្រឹងក្របខ័ណ្ឌស្ថាប័នឡើយ។ ទិន្នន័យដែលបានពីរូបថតពីអាកាសបង្ហាញថា នៅភូមិក្រឡា នៅក្នុងអំឡុងពេល ១៦ ឆ្នាំនៃរយៈពេលសិក្សានេះ តំបន់ការពារធម្មជាតិមិនបានរងការខូចខាតឡើយ ចំណែកវិសាលព្រៃឈើទាំង មូលបានថយចុះតាម អត្រាត្រឹមតែ ០.៨៦ % ប៉ុណ្ណោះក្នុងមួយឆ្នាំ។

## បរិបទសហគមន៍ និងអត្រានៃការបាត់បង់ព្រៃឈើ ឆ្នាំ ១៩៨៩-២០០៦

| ភូមិ | បរិបទរបស់សហគមន៍ | អត្រាបាត់បង់ព្រៃឈើ<br>ឆ្នាំ ១៩៨៩-២០០៦ |
|---|---|---|
| ភូមិក្រឡា | ការគ្រប់គ្រងតាមប្រពៃណីបានរឹងមាំ<br>ការគាំទ្រពីខាងក្រៅបានរឹងមាំ និងជាបន្តបន្ទាប់ | ០.៨៦% ក្នុងមួយឆ្នាំ |
| ភូមិឡឺគើន | អភិបាលកិច្ចតាមបែបប្រពៃណីមានភាពរឹងមាំជាបង្គួរ<br>ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលកាន់តែថយចុះ | ១.៦៣% ក្នុងមួយឆ្នាំ |
| ភូមិទុយ | ការចុះខ្សោយនៃស្ថាប័នសហគមន៍<br>ការរងសម្ពាធពីទីផ្សារកាន់តែខ្លាំងឡើង ដោយសារវាជាគោលដៅដំបូងនៃការបាត់បង់កម្មសិទ្ធិដី | ៥.០% ក្នុងមួយឆ្នាំ |

នៅក្នុងពេលដែលស្ថិតក្រោមកំណើនសម្ពាធបែបនេះ ការសិក្សានេះបានរកឃើញថា ប្រព័ន្ធគ្រប់គ្រងធនធានរបស់ជន ជាតិដើមភាគតិចខ្លះៗដែលកំពុងអនុវត្តនៅក្នុងខេត្តរតនៈគីរី ដូចជានៅក្នុងភូមិក្រឡា បានបង្ហាញអំពីសមត្ថភាពក្នុងការឆ្លើយតប ទៅនឹងគោលដៅរបស់ជាតិសម្រាប់ការប្រើប្រាស់ដោយនិរន្តរភាព និងការអភិរក្សព្រៃឈើ។ ប្រព័ន្ធទាំងនេះឆ្លើយតបបានយ៉ាងល្អទៅនឹងការគាំទ្រដែលផ្តោតទៅលើការបង្កើតឱ្យមានកិច្ចផ្តួចផ្តើមគ្រប់គ្រងព្រៃឈើនៅមូលដ្ឋាន និងការគាំទ្រសិទ្ធិសម្ងហភាពតាមប្រពៃណី។ ការសិក្សានេះក៏បង្ហាញផងដែរថាគ្រួសារជនជាតិដើមភាគតិច កំពុងស្ថិតនៅក្រោមសម្ពាធយ៉ាងធ្ងន់ធ្ងរឈានទៅរកការលក់ព្រៃសហគមន៍ដោយល្មើសច្បាប់ និងច្រើនតែតាមរយៈការក្លែងបន្លំដោយមន្ត្រីក្នុងមូលដ្ឋាន។ ព្រៃសហគមន៍ជនជាតិដើមតំណាងឱ្យឱកាសមួយសម្រាប់រដ្ឋាភិបាលកម្ពុជាក្នុងរក្សាទុកព្រៃឈើធម្មជាតិដ៏មានតម្លៃនៅក្នុងខេត្តរតនៈគិរីប្រសិនបើរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងម្ចាស់ជំនួយនានាអាចរកវិធីដើម្បីផ្តល់ការគាំទ្រប្រកបដោយ ប្រសិទ្ធិភាពដល់ប្រព័ន្ធកាន់កាប់ព្រៃឈើតាមប្រពៃណី។ យុទ្ធសាស្ត្របែបនេះអាចគាំទ្រដល់ការសម្រេចគោលដៅកម្រិតជាតិរបស់រដ្ឋាភិបាលក្នុងការរក្សាគម្របព្រៃឈើ ទន្ទឹមនឹងការឆ្លើយតបទៅនឹងតម្រូវការខាងសង្គមរបស់ប្រជាពលរដ្ឋនៅក្នុងខេត្តនេះដែលភាគច្រើនរស់នៅតាម ជនបទ។



## គោលបំណងនៃការស្រាវជ្រាវនេះ

របាយការណ៍នេះ មានគោលដៅរួមចំណែកក្នុងការសម្រេចគោលបំណងនានាដូចតទៅ :

- ដើម្បីបង្ហាញពីការប្រែប្រួល លើការប្រើប្រាស់ដីធ្លី គម្របព្រៃឈើ និងការត្រួតត្រាធនធាន ។
- កំណត់អត្តសញ្ញាណកម្លាំងជម្រុញនានា ដែលធ្វើឱ្យមានការប្រែប្រួលលើការប្រើប្រាស់ដីធ្លី និងកម្មសិទ្ធិជាពិសេសការបម្លែងព្រៃឈើ និងការបាត់បង់កម្មសិទ្ធិដីរបស់ជនជាតិដើមភាគតិច ។
- កំណត់អត្តសញ្ញាណ និងវាយតម្លៃកម្លាំងជម្រុញ ដែលរារាំងការប្រែប្រួលនានា ជាពិសេសប្រសិទ្ធិភាពនៃដំណើរការកសាងផែនការប្រើប្រាស់ដីធ្លីតាមបែបផែននៃការចូលរួម នៅក្នុងការផ្តល់ហេតុផលសមស្របសម្រាប់ការធ្វើឱ្យប្រែប្រួលគម្របដី និងការធ្វើឱ្យមានស្ថិរភាពចំពោះសិទ្ធីរបស់ជនជាតិដើមលើកម្មសិទ្ធិដីធ្លី ។
- វាយតម្លៃអំពីផលប៉ះពាល់ខាងផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថាននៃដីធ្លី និងការផ្លាស់ប្តូរកម្មសិទ្ធិដីធ្លីនៅក្នុងខេត្តរតនៈគីរី ក៏ដូចជាឥទ្ធិពលនៃផលប៉ះពាល់ទាំងនោះសម្រាប់អនាគតផងដែរ ។
- ផ្តល់អនុសាសន៍ដល់អ្នកកសាងគោលនយោបាយ និងអ្នកកសាងផែនការនៅក្នុងជួររដ្ឋាភិបាលក៏ដូចជា សហគមន៍ម្ចាស់ជំនួយដែលទាក់ទងនឹងជម្រើសនានា ដើម្បីដោះស្រាយបញ្ហាដីធ្លី និងព្រៃឈើ ដែលមានឥទ្ធិពលមកលើសហគមន៍ជនជាតិដើមភាគតិច នៅក្នុងប្រទេសកម្ពុជា ។

## វិធីសាស្រ្តស្រាវជ្រាវ

ការស្រាវជ្រាវនេះបានធ្វើឡើងនៅក្នុងឆ្នាំ ២០០៧ ក្រោមរូបភាពជាកិច្ចសហប្រតិបត្តិការរវាងអង្គការសហគមន៍ព្រៃឈើ អន្តរជាតិ (CFI) និងមជ្ឈមណ្ឌលខាងកើត-ខាងលិច(EWC) ។ អង្គការ CFI បាន និងកំពុងផ្តល់ការគាំទ្រដល់បណ្តាញសហគមន៍នៅក្នុងខេត្តនេះតាំង ពីឆ្នាំ ២០០៣ មក ចំណែកអ្នកស្រាវជ្រាវមកពី EWC បានចូលរួមក្នុងការសិក្សាតំបន់នេះច្រើនជាងមួយទសវត្សរ៍មកហើយ ។ គោលការណ៍ នៃវិធីសាស្រ្តនេះ គឺវិភាគរូបភាពពីផ្កាយរណបដែលថតបាននៅពេលវេលាខុសៗ គ្នា ដើម្បីកំណត់អត្ត សញ្ញាណនៃការប្រែប្រួលគម្រប ដី និងដើម្បី ធ្វើការសិក្សាឱ្យបានស៊ីជម្រៅជាមួយ សហគមន៍ (ទាំងនៅក្នុងការសម្ភាសក្រុមគោលដៅ និងការសម្ភាសជាបុគ្គល) ដើម្បីស្វែងយល់អំពីថាតើ



ហេតុអ្វីការប្រែប្រួលលើការប្រើប្រាស់ដីធ្លី និងកម្មសិទ្ធិកំពុងកើតឡើង និងធ្វើការវាយតម្លៃឥទ្ធិពលខាងសង្គមបណ្តាលពីការប្រែប្រួលទាំងនេះ ។

## សេណារីយ៉ូនៃការប្រែប្រួលលើការប្រើប្រាស់ដីធ្លីនៅខេត្តរតនៈគីរី

ស្លាកសញ្ញា ១៩ បកស្រាយអំពីសេណារីយ៉ូចំនួនបួន នៃស្ថានភាពជំនួសទៅអនាគត សម្រាប់ទីជម្រាលនៅក្នុងតំបន់ខ្ពង់រាបនៅដែនដីគោកនៃភូមិភាគអាស៊ីអាគ្នេយ៍ ។ យើងបានកែសម្រួលសេណារីយ៉ូទាំងនេះសម្រាប់ការពិភាក្សានេះ (រូបទី ១) ។ ទំព័របន្តបន្ទាប់ទាំងនេះ អធិប្បាយអំពីសេណារីយ៉ូទាំងបួននៃការប្រើប្រាស់ដីធ្លី ។

រូបទី ១ សេណារីយ៉ូនានានៃការប្រែប្រួលលើការប្រើប្រាស់ដីធ្លីទៅអនាគតនៅក្នុងខេត្តរតនៈគិរី




## *សេដ្ឋកិច្ចចំការដំណាំធំៗ*



សេណារីយ៉ូកំណើនសេដ្ឋកិច្ចនេះ នាំមុខដោយសារជំនួញក្នុងវិស័យកសិកម្ម។ ក្នុងពេលដែលកសិករមានចំណាប់អារម្មណ៍លើការដាំដំណាំមួយចំនួនសម្រាប់ទីផ្សារកៅស៊ូ (*Hevea brasiliensis*) គឺជាដំណាំពាណិជ្ជកម្មចំបង ដែលកំពុងតែជំនួសកសិកម្មព្រៃឈើ និងព្រៃលូតលាស់ឡើងវិញនៅក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ដែលនេះជាលទ្ធផលផ្ទាល់ដែលកើតចេញពី តម្រូវការខ្លាំងក្លានៅលើទីផ្សារក្នុងប្រទេសចិន ដែលជាអ្នកប្រើប្រាស់ធំជាងគេលើពិភពលោក។

នៅកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) មានផែនការពង្រីកផ្ទៃដីចំការដំណាំកៅស៊ូពី ៥០.០០០ ហិកតា ឱ្យដល់ ៨០០.០០០ ហិកតា រហូតដល់ឆ្នាំ ២០១៥ (ឬ ត្រូវជា ៤,៤% នៃផ្ទៃដីសរុបនៃប្រទេសកម្ពុជា)។ ឥទ្ធិពលខ្លះៗនៃ សេណារីយ៉ូនេះ គឺថារដ្ឋអាចដាក់ឱ្យប្រើប្រាស់គោលនយោបាយនានា ដែលសម្រួលដល់អ្នកជំនួញក្នុងការស្វែងរកផលចំណេញនៅ ក្នុងវិស័យកសិកម្មដែលអាច ឬ អាចមិនរាប់បញ្ចូល អ្នកដែលមានចំណែកដីតូចៗ។

ការពង្រីកដំណាំឯកវប្បកម្មជាទ្រង់ទ្រាយធំ អាចនាំឱ្យមានកំណើនភាពងាយរងគ្រោះពីសត្វចង្រៃ និងការរាតត្បាតនៃជម្ងឺ។ ការចិញ្ចឹមជីវិតរបស់កសិករ នឹងកាន់តែងាយរងគ្រោះដោយសារការប្រែប្រួលទីផ្សារ អាកាសធាតុ និងកត្តាផ្សេងៗទៀត។

### *ឧទ្យាន និងការអភិរក្ស*

គេអាចពិនិត្យមើលជម្រើសនៃការបញ្ចូលសហគមន៍នានា ទៅក្នុងប្រព័ន្ធតំបន់ការពារធម្មជាតិរបស់ជាតិ តាមរយៈការបង្កើត និងការទទួលស្គាល់តំបន់អភិរក្សសហគមន៍ (CCAs) ដែលត្រូវបានគេស្គាល់នៅក្នុងប្រទេសកម្ពុជាថាជា សហគមន៍តំបន់ ការពារធម្មជាតិ (CPAs)។ សហគមន៍ជាច្រើនដែលពឹងផ្អែកលើព្រៃឈើ មានប្រពៃណីការពារព្រៃឈើ ដែលរួមទាំង ព្រៃអ្នកតា ព្រៃបញ្ចុះសព ព្រៃក្បាលទឹកនិងព្រៃរបាំងខ្យល់ដែលអាចពង្រឹងជាបន្ថែមតាមរយៈគោលនយោបាយនិងកម្មវិធីរបស់រដ្ឋាភិបាល។ ទោះជាយ៉ាងណាក៏ដោយសូម្បីតែតំបន់ការពារធម្មជាតិដែលបានកំណត់ជាផ្លូវការ ដូចជា ឧទ្យានជាតិវិរជ័យ ក៏នៅតែងាយរង គ្រោះ ដោយសារការអនុវត្តនៃជម្រើសជំនួសផងដែរ។ ថ្មីៗនេះសិទ្ធិរុករករ៉ែនៅលើផ្ទៃដីមួយចំណែកធំនៃឧទ្យានជាតិវិរជ័យត្រូវបានផ្តល់ទៅឱ្យក្រុមហ៊ុនឯកជន។ នៅក្នុងទសវត្សរ៍នានាខាងមុខនេះនៅពេលដែលល្បឿននៃកំណើនសេដ្ឋកិច្ចក្នុងប្រទេសកម្ពុជាកើនឡើង គេនឹងទាមទារឱ្យមានឆន្ទៈនយោបាយខ្លាំងក្លាណាស់ទើបអាចរក្សាទុកតំបន់នានាសម្រាប់ការអភិរក្សបាន។



កិច្ចផ្តួចផ្តើមអភិរក្ស អាចដើរតួនាទីយ៉ាងសំខាន់នៅក្នុងការទ្រទ្រង់ដល់ការកាន់កាប់ដោយជនជាតិដើម និងប្រព័ន្ធការពារព្រៃឈើ ឬ នៅក្នុងការជម្លៀសពួកគេចេញ។ ភាគច្រើនគឺអាស្រ័យទៅលើយុទ្ធសាស្ត្រអភិរក្ស ដែលរដ្ឋាភិបាលប្រកាន់យក និងទីភ្នាក់ងារអនុវត្តនានា។ សហគមន៍នានា អាចដើរតួជាយុទ្ធសាស្ត្រ នៅក្នុងការត្រួតពិនិត្យកត្តានានាដែលជម្រុញឱ្យមានការបាត់បង់ព្រៃឈើ ជាពិសេសប្រសិនបើសិទ្ធិកាន់កាប់ធានធានរបស់ពួកគេត្រូវបានទទួលស្គាល់នៅក្រោមកិច្ចព្រមព្រៀងនៃកម្មវិធី អភិរក្ស។

### *ប្រព័ន្ធអេកូឡូស៊ីកសិកម្មបែបប្រពៃណី*

អស់រយៈពេលជាច្រើនសតវត្សរ៍មកហើយខេត្តរតនៈគីរីក៏ដូចជា ខេត្តនានានៅតំបន់ខ្ពង់រាបនៃដែនដីគោកក្នុងភូមិភាគអាស៊ីអាគ្នេយ៍ផងដែរ បានស្ថិតនៅក្រោមការគ្រប់គ្រងដោយក្រុមជនជាតិដើមតំបន់ភ្នំ ដែលមានទម្លាប់អនុវត្តខុសៗគ្នាខាងកសិកម្ម ដំណាំឆ្លាស់រយៈពេលវែងគួបផ្សំជាមួយការប្រមូលអនុផលព្រៃឈើ និងការបរបាញ់សត្វ។ ប្រព័ន្ធទាំងនេះកំពុងត្រូវបានជំនួសដោយប្រព័ន្ធផ្សេងទៀតនៅពេលដែលតម្រូវការសាច់ប្រាក់ក្នុងចំណោមសហគមន៍តំបន់ខ្ពង់រាប បានធ្វើឱ្យពួកគេកាន់តែងាកទៅរកការដាំដំណាំសម្រាប់លក់នៅលើចំណែកដីដដែលៗដោយមិនផ្លាស់ប្តូរ ហើយកំណើនសម្ពាធនៃចំនួនប្រជាជន និងថ្លៃដីធ្លី បានដាក់កំហិតទៅលើលទ្ធភាពរបស់ពួកគាត់ក្នុងការទទួលបានដីព្រៃដែលអាចអនុញ្ញាតឱ្យបាន ដើម្បីបំពេញតម្រូវការរបស់ពួកគាត់ក្នុងការ ទ្រទ្រង់ការធ្វើដំណាំឆ្លាស់តាមបែបពនេចរ។

Lebel (2006) អះអាងថា ដោយសារនិន្នាការបច្ចុប្បន្នខាងនយោបាយ និងសេដ្ឋកិច្ច ប្រព័ន្ធអេកូឡូស៊ីកសិកម្មបែបប្រពៃណីនឹងនៅតែបន្តបាត់បង់ លើកលែងតែមានការថយចុះជាបន្តបន្ទាប់នៃការវិនិយោគខាងហេដ្ឋារចនាសម្ព័ន្ធប្រចាំតំបន់នៅលើ ដីឯកជន និងសាធារណៈ ឬដោយសារមូលនិធិទាំងនេះត្រូវផ្តោតទៅកន្លែងផ្សេង ឬមួយដោយសារការមិនរីកចម្រើនរយៈពេលវែង នៃសេដ្ឋកិច្ចពិភពលោក។

### ប្រព័ន្ធអេកូឡូស៊ីកសិកម្មខុសៗគ្នា

នៅក្រោមសេណារីយ៉ូនេះ កំណើនសេដ្ឋកិច្ចយ៉ាងច្រើន ប៉ុន្តែប្លែកៗគ្នា នឹងកើតមានឡើង ប៉ុន្តែវានឹងត្រូវពឹងផ្អែកលើភាពប្រកួតប្រជែងនៅមូលដ្ឋាន ខាងផ្នែកកសិកម្ម ទេសចរណ៍ និង អាចខាងផ្នែកយករ៉ែផងដែរ ជាងលើការប្រើប្រាស់បច្ចេកវិទ្យា និង ប្រព័ន្ធផលិតកម្ម ដែលកាន់តែមានលក្ខណៈឯកសណ្ឋាន។ សេណារីយ៉ូនេះ នឹងតម្រូវឱ្យគោលនយោបាយរបស់រដ្ឋាភិបាលទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិច ដែលរួមបញ្ចូលឧទ្យានជាតិទៅក្នុងតំបន់ទេសភាពធំទូលាយ និង ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូន និងទំនាក់ទំនងដែលមានវិសាលភាពគ្រប់គ្រាន់ ដើម្បីបំពេញតាមតម្រូវការនៃការផលិតដំណាំនៅក្នុងមូលដ្ឋាននោះ និងទេសចរណ៍លើផ្អែកអេកូឡូស៊ីកសិកម្ម។ នេះអាចជាសេណារីយ៉ូដែលល្អជាងគេ ក្នុងចំណោមសេណារីយ៉ូដែលមានគូសបញ្ជាក់នៅទីនេះ បើគិត អំពី-កិច្ចការពារសិទ្ធិប្រើប្រាស់ធនធាននៅមូលដ្ឋាន និងការអភិវឌ្ឍដោយចីរភាព។ ការចិញ្ចឹមជីវិតរបស់កសិករ នឹងត្រូវពឹងផ្អែកលើការធានាសិទ្ធិលើកម្មសិទ្ធិក៏ដូចជា ផលិតផលកសិកម្មច្រើនមុខសម្រាប់ទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិផងដែរ។

### សេចក្តីសន្និដ្ឋាន

ដីធ្លីដែលជាមុខទំនិញមួយនៅលើទីផ្សារមានទំនាស់ជាមួយទស្សនៈទាននៃការគ្រប់គ្រងដីធ្លីរបស់ជនជាតិដើមភាគតិចដែលចាត់ទុកដីធ្លី និងព្រៃឈើថាជាធនធានសម្ងួហភាពដែលត្រូវរក្សាមិនប៉ះពាល់សម្រាប់មនុស្សជាច្រើនជំនាន់ទៅខាងមុខ។ នៅពេលដែលធនធានធម្មជាតិកាន់តែខ្សត់ទៅៗ កំណើនចំនួនប្រជាជនទាំងតាមរយៈកំណើន ដោយធម្មជាតិ និងការធ្វើចំណាក ស្រុក រួមផ្សំជាមួយ អំពើពុករលួយ ការពង្រីកសេដ្ឋកិច្ច គឺជាការប្រឈមនឹងភាពគង់វង់នៃគំរូគ្រប់គ្រងដីធ្លីតាមបែបប្រពៃណី។ ទោះជាយ៉ាងណាក៏ដោយមានសហគមន៍ជនជាតិដើមភាគតិចយ៉ាងច្រើននៅ លើពិភពលោក ដែលគ្រប់គ្រងផ្ទៃដីធំធេងដោយ ទទួលបានផលចំណេញ និងមាននិរន្តរភាពនៅក្រោម រូបភាព-ជាដីកម្មសិទ្ធិសមូហភាព ទន្ទឹមនឹងផ្តល់ជាផលប្រយោជន៍ជាតិយ៉ាងច្រើន និង សេវាបរិស្ថានផងដែរ។ ការគ្រប់គ្រងរបស់ជនជាតិដើម ភាគតិច និងកម្មសិទ្ធិសមូហភាពមិនសុទ្ធតែមានទំនាស់ជាមួយប្រព័ន្ធ ផលិតកម្មកសិកម្ម និងព្រៃឈើតាមបែបពាណិជ្ជកម្មសម័យទំនើបនេះទេ ហើយតាមពិត វាអាចជួយពង្រឹងអន្តរកាល និងនិរន្តរភាព នៃការវិវត្តផ្នែកកសិកម្មផងដែរ។

សហគមន៍ជនជាតិដើមភាគតិចនៅក្នុងខេត្តរតនៈគីរី កំពុងធ្វើការផ្លាស់ប្តូរជាបណ្តើរៗនូវប្រព័ន្ធប្រើប្រាស់ដីធ្លីរបស់ខ្លួនដែលឆ្លើយតបនឹងការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងលើដំណាំសម្រាប់លក់ជាពិសេសស្វាយចន្ទី។ នៅភូមិក្រឡា តាមរយៈការរក្សាទុកកម្មសិទ្ធិ សមូហភាព អ្នកភូមិនេះអាចបង្កើនការដាំស្វាយចន្ទីបើប្រៀបធៀបនឹងសហគមន៍នៅក្បែរខាង និងសម្រេចបានសមធមិកម្រិតខ្ពស់នៅក្នុងដំណើរការនេះ។ ដំណើរការមួយប្រកបដោយប្រសិទ្ធភាពនៃការកសាងផែនការប្រើប្រាស់ដីធ្លី បានធានាថាសហគមន៍នៅភូមិក្រឡារក្សាព្រៃអភិរក្ស ក៏ដូចជាដែនបម្រុងព្រៃឈើសម្រាប់ផលិតកម្មបានគង់វង់ក្នុងទំហំគ្រប់គ្រាន់ដែលអាចអនុញ្ញាតឱ្យពួកគេបន្តធ្វើកសិកម្មពនេចរ និងការពង្រីកន្លែងដាំស្វាយចន្ទីបានផងដែរ។ បទពិសោធន៍នេះបង្ហាញពីភាពផ្ទុយគ្នាស្រឡះ ជាមួយភូមិទុយដែលកង្វះសុវត្ថិភាពខាងកម្មសិទ្ធិដីធ្លី និងភាពក្រីក្របានធ្វើឱ្យមានដំណើរការបាត់បង់កម្មសិទ្ធិដីធ្លីយ៉ាងឆាប់រហ័សដែលបង្ខំឱ្យអ្នកភូមិនៅក្នុងមូលដ្ឋាននេះរាន



ផ្ការចំការថ្មីៗនៅក្នុងព្រៃតាមកន្លែងដាច់ស្រយាលដែលកាលពីអតីតកាលត្រូវបានចាត់ទុកថាជា "តំបន់ការពារធម្មជាតិ" ។ នៅភូមិទុយ និង ភូមិឡឺតើន ការរៀបចំឯកសារ "ដំណើរការកសាងផែនការប្រើប្រាស់ដីធ្លីតាមបែបផែននៃការចូលរួម - PLUP " បានផ្តល់ប្រសិទ្ធិភាពបន្តិចបន្តួចតែប៉ុណ្ណោះនៅក្នុងការ តម្រង់ទិសការផ្លាស់ប្តូរលើការប្រើប្រាស់ដីធ្លី និងកិច្ចការពារសិទ្ធិលើដីធ្លីរបស់ជនជាតិដើម បើទោះជានៅក្នុងករណីភូមិក្រឡា ឧបករណ៍ទាំងនេះអាចផ្តល់ ប្រសិទ្ធិភាពខ្ពស់ក៏ដោយ បើផ្អែកលើការពង្រីកបន្ថែម នូវការកសាងសមត្ថភាពសហគមន៍ ។

ទោះជាយ៉ាងណាក៏ដោយ គេមានបរិធានច្បាប់ថ្មីៗ ដែលអាចយកមកប្រើប្រាស់ដើម្បីរក្សាស្ថិរភាពនៃស្ថានភាពកម្មសិទ្ធិដីធ្លីនៅក្នុងខេត្តរតនះគីរី និងកំហិតទៅលើការលក់ដីធ្លីដោយល្មើសច្បាប់ ។ នៅក្នុងអំឡុងពេលនៃទសវត្សរ៍កន្លងទៅរាជរដ្ឋាភិបាលកម្ពុជាបានតាក់តែងសេចក្តីព្រាងច្បាប់ភូមិបាលថ្មីមួយ ច្បាប់ស្តីពីព្រៃឈើ និងអនុក្រឹត្យស្តីពីសហគមន៍ព្រៃឈើដែលសុទ្ធតែមានចែងអំពីប្រការនានា ដែលអាចជួយ ធានាឱ្យមានការប្រើប្រាស់ធនធានធម្មជាតិកាន់តែមានសមធម៌ និងនិរន្តរភាព ។ ជាសំណាងអាក្រក់ដោយសារកង្វះធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស និងការប្រឈមជាមួយការប្រកួតប្រជែងខាងគោលនយោបាយ និងរបៀបវារៈនយោបាយនានា គោលនយោបាយទាំងនេះ និងច្បាប់នានា នៅពុំបានដាក់ឱ្យប្រតិបត្តិការ និងអនុវត្តប្រកបដោយប្រសិទ្ធិភាពនៅឡើយទេ ។ ដោយមានការគាំទ្រពីសហគមន៍ម្ចាស់ជំនួយនានា រាជរដ្ឋាភិបាលកម្ពុជាត្រូវតែឈានទៅមុខដោយគិតទុកជាមុនដើម្បីប្រើប្រាស់យន្តការច្បាប់នានាដែលមានស្រាប់សម្រាប់គាំទ្រកិច្ចប្រឹងប្រែងនានារបស់សហគមន៍ជនជាតិ ដើមភាគតិចក្នុងការរក្សាស្ថិរភាពធនធានព្រៃឈើ និងដីធ្លីនៅក្នុងរយៈពេលនៃទសវត្សរ៍នានា ខាងមុខនេះ ។



យើងបានឃើញច្បាស់ហើយថា ការប្រើប្រាស់ដីធ្លីកំពុងប្រែប្រួលយ៉ាងឆាប់រហ័សនៅក្នុងភូមិទាំងបីដែលបានសិក្សាដែលឆ្លុះបញ្ចាំង អំពីទម្រង់រួមដែលកើតឡើងនៅក្នុងខេត្តរតនះគីរី និងតំបន់នានាផ្សេងទៀតនៅក្នុងតំបន់ខ្ពង់រាបនៃដែនដីគោកក្នុងភូមិភាគអាស៊ីអាគ្នេយ៍ ។ ការប្រែប្រួលទាំងនេះខ្លះឆ្លុះបញ្ចាំងអំពីអន្តរកាល នៃកសិកម្មទូលំទូលាយពីទម្រង់នានានៃកសិកម្មពនេចរទៅរកការធ្វើដំណាំពាណិជ្ជកម្មសម្រាប់លក់ជាពិសេសការដាំស្វាយចន្ទី ។ ការធ្វើវិប្បកម្មបែបពាណិជ្ជកម្មបានបង្កើតឱ្យមានប្រភពថ្មីៗនៃប្រាក់ចំណូលសម្រាប់គ្រួសារជនជាតិដើមជាច្រើន ទន្ទឹមនឹងការសម្រួលទីផ្សារដីធ្លី និងការបង្កើនល្បឿននៃការបាត់បង់កម្មសិទ្ធិដីធ្លី ។ សហគមន៍នានា ដូចជានៅភូមិក្រឡាដែលបាន

ពង្រឹងស្ថាប័នជនជាតិដើមភាគតិចរបស់ខ្លួន និងបានបង្កើតគោលនយោបាយច្បាស់លាស់អំពីការប្រើប្រាស់ដីធ្លី និងកម្មសិទ្ធិដីធ្លីកំពុងតែប្រើប្រាស់ឱកាសទីផ្សារថ្មីមួយដោយជោគជ័យ ទន្ទឹមនឹង ការរក្សាធនធានព្រៃឈើ និងស្ថាប័នវប្បធម៌របស់ខ្លួនឱ្យមាននិរន្តរភាពផងដែរ ។

ផ្ទុយទៅវិញ សហគមន៍នានា ដូចជា នៅភូមិទុយ កំពុងតែបម្លែងយ៉ាងឆាប់រហ័សទៅជាតំបន់នានា ដែលអ្នកភូមិលក់ដីធ្លីរបស់ខ្លួន និងអ្នកធ្វើចំណាកស្រុកចូលទៅក្នុងតំបន់ទាំងនោះ ។ នៅក្នុងពេលសព្វថ្ងៃនេះ ភូមិជាច្រើននៅក្នុងខេត្តរតនះគីរី ដូចជា ភូមិឡឺតើនកំពុងប្រឹងប្រែងតស៊ូដើម្បីរក្សាជីវភាព និងព្រៃឈើរបស់ខ្លួន នៅចំពោះមុខនៃសម្ពាធដែលកំពុងតែកើនឡើង ។ បើទោះបីសហគមន៍ទាំងនេះអាចនឹងមានភ័ព្វវាសនាដូចជា ភូមិទុយ និងប្រឈមជាមួយបទពិសោធន៍នៃប្រើប្រាស់ដីធ្លីយ៉ាងច្របូកច្របល់ និងការផ្លាស់ប្តូរកម្មសិទ្ធិក៏ដោយ ឬមួយអាចរក្សាបាននូវស្ថិរភាពធនធានរបស់ពួកគេ ដូចជា នៅភូមិក្រឡា និង ការធ្វើ ដំណើរជាលក្ខណៈប្រព័ន្ធទៅរកគំរូថ្មីៗនៃផលិតកម្មក៏ដោយវានឹងត្រូវពឹងផ្អែកលើកត្តានានាមួយចំនួន ។ សូម្បីតែភូមិក្រឡាក៏អាចរងការបាក់បែកផងដែរ ប្រសិនបើគ្មានការគោរពប្រព័ន្ធនានា

ខាងសង្គមទេនោះ។ កត្តាគន្លឹះមួយគឺវិសាលភាពនៃការគាំទ្រពីទីភ្នាក់ងារនានាមកពីក្រៅដែលសហគមន៍នានាទាំងនេះ នឹងទទួលបានដែលរួមទាំងការគាំទ្រពីអង្គការមិនមែនរដ្ឋាភិបាល និងកម្មវិធីនានារបស់រដ្ឋាភិបាល និងកិច្ចការពារខ្លះៗដែលទទួលបានពីឈ្មួញទិញលក់ដីខុសច្បាប់។ នៅក្នុងភូមិដែលបានសិក្សាអ្នក ភូមិបានកត់សំគាល់អំពីសារៈសំខាន់នៃអង្គការមិន មែនរដ្ឋាភិបាលនៅក្នុងការ ជួយពួកគេរក្សាទុកដីធ្លីសមូហភាព និងរៀនសូត្រអំពីរបៀបធ្វើការជាមួយអាជ្ញាធរមូលដ្ឋាន និងកម្លាំងនៃទីផ្សារ។ ការ សិក្សានេះក៏បានបង្ហាញផងដែរថា ការកសាងសហគមន៍រយៈពេលវែងប្រកបដោយនិរន្តរភាព គឺជាគន្លឹះមួយឆ្ពោះទៅរកជោគជ័យនៅក្នុងការបង្កើតស្ថាប័នសហគមន៍ដែលស្ថិតស្ថេរដែលអាចតម្រង់ទិសការបង្កើតគោលនយោបាយអំពីការប្រើប្រាស់ដីធ្លី និង កម្មសិទ្ធិលើ ដីធ្លី។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក បានផ្តល់វិភាគទានយ៉ាងច្រើនដល់សហគមន៍ជនជាតិដើមនៅក្នុងខេត្តរតនៈគិរី ហើយពួកគេក៏ត្រូវតែបង្កើនសមត្ថភាពខ្លួនឯងផងដែរ ទាំងលើជំនាញ និងវិសាលភាពនៃអន្តរាគមន៍។

ពួកគេក៏ត្រូវតែស្វែងរកវិធីនានាដើម្បីធ្វើសមាហរណកម្មជាបន្ថែមទៀតជាមួយស្ថាប័នជនជាតិដើមភាគតិចផងដែរ ដើម្បីបង្កើតបានច្រើននូវភាពជាម្ចាស់ក្នុងចំណោមសហគមន៍។ គេត្រូវតែលើកតំកើងផងដែរនូវបណ្តាញសហគមន៍ដែលពុំសូវពឹងផ្អែកលើរចនាសម្ព័ន្ធរបស់ប្រជាពលរដ្ឋមិនមែនជាជនជាតិដើម ដើម្បីពង្រឹងស្ថាប័នសង្គមស៊ីវិលនៅក្នុងខេត្តរតនៈគិរី។

ទីបំផុតមន្ត្រីរដ្ឋាភិបាលនៅថ្នាក់មូលដ្ឋាន និងមេដឹកនាំសហគមន៍ត្រូវការឱ្យមានការបណ្តុះបណ្តាល និងការណែនាំលើគោលនយោបាយដីធ្លីនៅថ្នាក់ជាតិ និងក្របខ័ណ្ឌបើកចំហ និងតម្លាភាពមួយសម្រាប់ការពិភាក្សានៅថ្នាក់ឃុំ ស្រុក និងថ្នាក់ខេត្ត ផងដែរ។ គេមានតម្រូវការជាបន្ទាន់ដើម្បីធ្វើការបញ្ជាក់អំពីសិទ្ធិ និងការទទួលខុសត្រូវលើការគ្រប់គ្រងដីធ្លី និងធនធានព្រៃឈើនៅទូទាំងខេត្ត ជាពិសេសនៅក្នុងកិច្ចប្រឹងប្រែងមួយដើម្បីការពារចំណែកដីពីដូនតា របស់សហគមន៍ជនជាតិដើមភាគតិចនៅក្នុង តំបន់នេះ។ រដ្ឋបាលព្រៃឈើ មានតួនាទី និងការទទួលខុសត្រូវដើម្បីកំណត់ព្រំប្រទល់ដីព្រៃដែលជាកម្មសិទ្ធិសាធារណៈរបស់រដ្ឋ និងកំណត់តំបន់ណាខ្លះដែលរដ្ឋបាលព្រៃឈើទទួលស្គាល់ថាមានលក្ខណៈសមស្របសម្រាប់កំណត់ជាសហគមន៍ព្រៃឈើ។ រដ្ឋបាលព្រៃឈើក៏មានតួនាទីសម្របសម្រួលជាមួយក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ផងដែរ ដើម្បីកំណត់ដីសម្រាប់បញ្ចូល ជាកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិច។ ក្នុងពេលដែលគេមានក្របខ័ណ្ឌច្បាប់ជាច្រើនរួចមកហើយ ដើម្បីចាប់ផ្តើមបង្កើតទីតាំងសហគមន៍ព្រៃឈើដែលមានការទទួលស្គាល់ និងដើម្បីចាប់ផ្តើមចេញប័ណ្ណកម្មសិទ្ធិសមូហភាព គេត្រូវតែ ផ្តល់អាទិភាពលើការកៀងគរ និងពង្រឹងសហគមន៍ផងដែរ។

ការកំណត់ដីសម្បទានសេដ្ឋកិច្ច មិនត្រូវឱ្យជាន់ជាមួយដីធ្លីរបស់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិចឡើយ។ ដីសម្បទានសេដ្ឋកិច្ចកំពុងបង្កើតជាទំនាស់ និងបង្កឱ្យមានចំណាកស្រុកទន្ទឹមនឹងការមិនបង្ហាញថាជាកត្តាដែលមានប្រសិទ្ធិភាពក្នុងការជម្រុញ កំណើនសេដ្ឋកិច្ចឡើយ។



ដូចដែលរបាយការណ៍មួយរបស់អង្គការសហប្រជាជាតិបានសន្និដ្ឋានថា ៖

*ដីសម្បទានសេដ្ឋកិច្ចពុំបាននាំឱ្យមានកំណើនផលិតភាពកសិកម្ម ឬ កំណើនសេដ្ឋកិច្ចដល់ប្រទេសកម្ពុជាឡើយ ហើយវិសាលភាពធំធេងនៃផ្ទៃដីដែលបានផ្តល់ជាសម្បទានត្រូវបានទុកចោល ឬ ប្រើប្រាស់មិនពេញសក្តានុពលរបស់វាឡើយ។ ដូចក្នុងអនុសាសន៍នៃរបាយការណ៍វាយតម្លៃភាពក្រីក្រធ្វើឡើងដោយធនាគារពិភពលោក ឆ្នាំ ២០០៦ បានបញ្ជាក់ការធានាកម្មសិទ្ធិដី និងកសិកម្មប្រចាំគ្រួសារ ឬម្ចាស់កម្មសិទ្ធិដីតូចតាចអាចនឹងកែលំអសមិទ្ធិផលនៃការអភិវឌ្ឍសម្រាប់សហគមន៍ជនបទ។ កិច្ចផ្តួចផ្តើមដែលផ្អែកលើសហគមន៍ សម្រាប់ការគ្រប់គ្រងដីធ្លី និងធនធានធម្មជាតិ គួរតែត្រូវបាន ចាត់ទុកជាអាទិភាព។*

តំបន់ទេសភាពនៅក្នុងខេត្តរតនៈគិរី កំពុងរងការបំផ្លែងនៅពេលដែលព្រៃឈើកំពុងត្រូវបានរានឆ្ការតាមអត្រាដែលត្រូវបានប៉ាន់ប្រមាណថាមាន ៥% នៅតាមបណ្តោយផ្លូវជាតិលេខ ៧៨ ដែលលាតសន្ធឹងពីទន្លេមេគង្គនៅក្នុងភាគខាងលិចរហូតដល់ព្រំប្រទល់ប្រទេសវៀតណាមនៅភាគខាងកើត។ ការសិក្សានេះបង្ហាញថាសហគមន៍ដែលរស់នៅតាមប្រពៃណីក្នុងខេត្តរតនៈគិរីបានបាត់បង់ព្រៃឈើរបស់ខ្លួនជិត ៤០% នៅក្នុងរយៈពេល ១៦ ឆ្នាំកន្លងមកនេះ។

តាមអត្រានៃការរានឆ្ការដូចសព្វថ្ងៃនេះ ព្រៃឈើទាំងអស់នៅភូមិទុយ នឹងត្រូវបាត់បង់អស់នៅមុនឆ្នាំ២០០៨។ ការទិញដីដោយវិនិយោគិនមកពីក្រៅភាគច្រើនជាការទិញដោយល្មើសច្បាប់កំពុងតែធ្វើឱ្យគ្រួសារនានានៅក្នុងមូលដ្ឋានធ្វើចំណាកស្រុកយ៉ាងឆាប់រហ័ស ដោយត្រូវភៀសខ្លួនចូលទៅរស់នៅក្នុងព្រៃកាន់តែជ្រៅទៅៗ ដែលជាកន្លែងធ្លាប់បានកំណត់ជាតំបន់អភិរក្ស ដើម្បីបង្កើតកន្លែងថ្មីសម្រាប់ធ្វើកសិកម្ម។ អ្នកផ្តល់ចម្លើយនៅក្នុងសហគមន៍នៃភូមិទុយបានប៉ាន់ប្រមាណថាជិត៨០%នៃគ្រួសារទាំងអស់បានលក់ដីរបស់ខ្លួនទៅឱ្យអ្នកចំណាកស្រុក និងវិនិយោគិនរួចទៅហើយ ដែលករណីជាច្រើនកើតឡើងដោយសារមានការបង្ខាប់បញ្ជា។ នៅពេលដែលបានរានឆ្ការព្រៃរួចហើយ ដីនោះនឹងត្រូវដាំកៅស៊ូ ឬស្វាយចន្ទីជាជំនួស។ បើទោះជាដំណើរការបម្លែងដីព្រៃទៅជាដីដាំដំណាំ និងការបាត់បង់កម្មសិទ្ធិដីរបស់ជនជាតិដើម បានកើតឡើងច្រើននៅក្នុងភូមិទុយក៏ដោយ សហគមន៍ផ្សេងៗ ទៀត កំពុងតែអនុវត្តតាមទម្រង់ទាំងនេះស្ទើរតែដូចគ្នាទាំងស្រុង ហើយកំពុងតែសាយភាយនៅទូទាំងកន្លែងជាច្រើនក្នុងខេត្តនេះ ផងដែរ។ បញ្ហានានាដែលមានបង្ហាញជូនតាមរយៈការប្រែប្រួលយ៉ាងឆាប់រហ័សនេះ មានទាក់ទងទៅនឹងបញ្ហាយុត្តិធម៌សង្គម និង ភាពនៅជាប់ជាបន្ត សមធម៌សេដ្ឋកិច្ច និងការផ្តល់សេវាបរិស្ថានផងដែរ។ ការបាត់បង់កម្មសិទ្ធិដីគឺជាបញ្ហាទូទៅសម្រាប់ប្រជាពលរដ្ឋជាជនជាតិដើមភាគតិច។ ការបាត់បង់ដីដូនតានាំឱ្យមានការបាត់បង់អត្តសញ្ញាណវប្បធម៌ ជាពិសេសសម្រាប់វប្បធម៌នានា ដែលកាន់កាប់ដីធ្លី និងធនធានព្រៃឈើជាសមូហភាពរបស់ពួកគេ ដូចជាករណីដែលកើតឡើងចំពោះប្រជាជននៅខេត្តរតនៈគិរីជាឧទាហរណ៍ស្រាប់។ ការទិញដីដោយល្មើសច្បាប់ និងការផ្តល់ដីសម្បទានសេដ្ឋកិច្ចកំពុងកើនឡើងយ៉ាងឆាប់រហ័ស ដែលជាញឹកញាប់កើតឡើងដោយមានការ សម្រុបសម្រួលពីមន្ត្រីរដ្ឋាភិបាលនៅមូលដ្ឋាន ជាការប្តូរនឹងប្រាក់ទឹកតែ។ សហគមន៍ដែលបាត់បង់សិទ្ធិអំណាច និងក្រីក្រត្រូវការជាបន្ទាន់នូវការអនុវត្ត ទាំង



គោលនយោបាយ និងកម្មវិធីនានា ដែលការពារពួកគេពីការកេងប្រវ័ញ្ច។ កិច្ចការនេះ ត្រូវតែចាប់ផ្តើមនៅកម្រិតមូលដ្ឋានបំផុត ដោយអនុវត្ត រដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជា និងច្បាប់ភូមិបាលឆ្នាំ ២០០១ មុននឹងតាក់តែងគោលនយោបាយ និងច្បាប់ថ្មីៗជាបន្ថែម។

ករណីនៅភូមិក្រឡា បង្ហាញថាវិធានការគាំទ្ររបស់រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល អាចបង្កើតបរិយាកាសនានា ដែលប្រជាពលរដ្ឋជាជនជាតិដើមភាគតិច អាចរក្សាទុកអត្តសញ្ញាណ ទន្ទឹមនឹងចូលរួមប្រកបដោយជោគជ័យនៅក្នុងសេដ្ឋកិច្ច ទីផ្សារ ការគាំទ្រគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងការអនុវត្តអន្តរកាលនៃកសិកម្មដោយនិរន្តរភាពផងដែរ។ គេត្រូវតែពង្រឹង ជាបន្ថែមនូវការគ្រប់គ្រងសហគមន៍ ដើម្បីដោះស្រាយទំនាស់ដែលកាន់តែកើនច្រើនឡើងទាក់ទងនឹងដីធ្លី និងព្រៃឈើ។ នៅខេត្តរតនៈគីរី អង្គភាពធ្វើសេចក្តីសម្រេចតាមប្រពៃណីសម្រាប់អភិបាលកិច្ចនិងការដោះស្រាយទំនាស់គឺមាននៅកម្រិតភូមិ។ រាជរដ្ឋាភិបាលកម្ពុជាមានក្របខ័ណ្ឌច្បាប់ និងគោលនយោបាយចាំបាច់រួចទៅហើយ ដើម្បីការពារសិទ្ធិលើធនធានរបស់ប្រជាពលរដ្ឋដែលពឹងផ្អែកលើព្រៃឈើ។ ឥឡូវនេះរដ្ឋាភិបាលត្រូវតែបង្ហាញអំពីឆន្ទៈនយោបាយដើម្បីពង្រឹង និងអនុវត្តយ៉ាងសកម្មនូវក្របខ័ណ្ឌនេះ។ ប្រជាជននៅខេត្តរតនៈគីរី មានចំណេះដឹងស៊ីជម្រៅអំពីបរិស្ថានរបស់ខ្លួន ដែលមានគុណតម្លៃប្រកបដោយសក្តានុពលយ៉ាងធំធេងសម្រាប់បង្កើតការសម្រេចលើការគ្រប់គ្រង ក៏ដូចជា ការដើរតួយ៉ាងសកម្មនៅក្នុងកំណើនសេដ្ឋកិច្ចកម្ពុជាផងដែរ។

